# សរុបព្រឹត្តការណ៍ប្រចាំ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០
## សម្រាប់ វីរុស COVID-19

## ១. កោះសន្តិភាព៖ ក្រសួងសុខាភិបាលបង្ហាញពីបង្ការការឆ្លងមេរោគ និងត្រូវប្រុងប្រយ័ត្ន



Tiger STREET FOOTBALL 2020 ស្វែងចេញនូវភាពកាចចិត្ត ដ៏មោះមុតរបស់អ្នក ប្រាក់រង្វាន់សរុបរហូតដល់ $50,000 UNCAGE YOUR TIGER

### ក្រសួងសុខាភិបាលបង្ហាញពីបង្ការការឆ្លងមេរោគ និងត្រូវប្រុងប្រយ័ត្ន

ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២០ ម៉ោង ០៩:១៤ អ៊ាង ប៊ុនរិទ្ធ Share



រាជធានីភ្នំពេញ ៖ ក្រសុខាភិបាលបានធ្វើសន្និសីទបង្ហាញពីរបៀបនៃការបង្ការចំលងមេរោគបានរយៈខ្យល់ ហើយត្រូវមានការប្រុងប្រយ័ត្ន ដើម្បីចៀសវាងការចម្លងជំងឺពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។ លោក បណ្ឌិត លី សូវ៉ាន់ ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង និងជាអ្នកនាំពាក្យរបស់ក្រសួងសុខាភិបាលបានឲ្យដឹងនៅថ្ងៃទី២៥ ខែកុម្ភៈនេះ ដោយបានលើកឡើងថា ការឆ្លងមេរោគធំៗរបស់មេរោគមានពីរ គឺការឆ្លងតាមខ្យល់ និងឆ្លងតាមដំណកតូចៗដូចជាការកណ្តាស់ ក្អកជាដើម ។

អត្រាប្តូរប្រាក់
ប្រាក់រៀល (1USD) KHR 1USD : 4087
អត្រាប្តូរប្រាក់ផ្សេងទៀត

TODAY internet GET CONNECTED TO THE WORLD 070 21 5577 www.today.com.kh

SPONSORED NEWS

០៩:២០ | ក្នុងស្រុក
គម្រោង The Peak កំពុងស្ថិតក្នុងភាពចម្រូងចម្រាស់ជាមួយក្រុមហ៊ុនម៉ៅការសំណង់

ជំងឺដែលឆ្លងតាមខ្យល់មានជំងឺ ឬមេរោគរបេង មេរោគស្អូច កញ្ជ្រិល អុតស្វាយ ។ លោកវេជ្ជបណ្ឌិតបន្តថា មេរោគឆ្លងតាមខ្យល់នេះទោះបីជាពាក់ម៉ាស់យ៉ាងណាក៏មិនអាចការពារបានដែរ គឺវាអាចច្រេះចូលតាមប្រហោងតាមម៉ាស់ធំជាង ប៉ុន្តែអាចការពារបានទាល់តែពាក់ម៉ាស់របស់ពេទ្យបានទប់ជាប់ ។ ចំពោះការឆ្លងតាមដំណក់ទឹកតូចៗវិញមានន័យថា នៅពេលដំណក់ទឹកតូចៗចេញពីអ្នកជំងឺដល់កន្លែងណាមេរោគដល់ទីនោះជាក់ស្តែងមានជំងឺខាន់ស្លាក់ ជំងឺផ្តាសាយ និងក្ឋរ៉ូណាវីរុសជាដើម ។ លោកបញ្ជាក់ថា ៖«ពេលដំណក់ទឹកតូចៗដល់ទីណាមេរោគទៅដល់ទីនោះ ។ ដំណើកទឹកនឹងកើតមកពីការក្អកកណ្តាស់ ។

ការសិក្សាកណ្តាស់ ក្អកនេះអាចមានចំងាយជិត១ម៉ែត្រ ។ នៅពេលក្អកកន្លែងណាទឹកនឹងនៅទីនោះ ។ អីចឹងបានគេឲ្យពាក់ម៉ាស់ ដើម្បីចៀសវាងការឆ្លងអ្នកជំងឺគួតែពាក់ម៉ាស់ ដើម្បីកុំស្តាត់នៅពេលកណ្តាស់ ហើយឆ្លងទៅគេ ។ ជាងនេះអ្នកកណ្តាស់ត្រូវឧស្សាលាងដៃ និងសាប៊ូ» ។ លោកវេជ្ជបណ្ឌិតក៏បានលើកឡើងថាសម្រាប់អ្នកជាវិញ មិនចាំពាក់ម៉ាស់ទេ ប៉ុន្តែឧស្សាហ៍លាងដៃ និងសាប៊ូបន្តិច ព្រោះថា អ្នកជាឧស្សាហ៍ប៉ះពាល់និងទីកន្លែងផ្សេងៗដែលជាហេតុនាំឲ្យមេរោគឆាប់ឆ្លងនៅពេលយកដៃទៅញីប្រមុះ មាត់ ភ្នែក ។

លោកបញ្ជាក់ថា ៖«អ្នកជា ឬមនុស្ស ដើម្បីទប់ស្កាត់ការឆ្លងជំងឺត្រូវកាត់បន្ថយការយកដៃប៉ះផ្ទៃមុខជាអតិបរមាកាន់តែច្រើនកាន់តែល្អ ។ យើងបង្ហាញថ្ងៃនេះមិនសម្រាប់ជំងឺកូរ៉ូណាទេ ជំងឺផ្សេងទៀតក៏ទប់ស្កាត់ការឆ្លងដែរ» ។

លោក វេជ្ជបណ្ឌិត លីស្វាន់ ក៏បានលើកឡើងទៀតថា ដៃប្រៀបដូចជា វត្ថុមួយចំនួនជំងឺ ឬអាចនិយាយថាដូចជា ពីងអីចឹង ព្រោះថា ដៃបានប៉ះពាល់ទីកន្លែងច្រើន ហើយដៃលជាហេតុនាំឲ្យមេរោគឆាប់ឆ្លង ។ ដៃយើងជាអ្នកចំឆ្លង ហើយបណ្តាលឲ្យមានអាលាក់ស៊ីកើតលើកផ្ទៃមុខ ព្រោះថា ដៃមានសារធាតុច្រើន ។ ជាមួយគ្នានោះដែរ លោកវេជ្ជបណ្ឌិតក៏បានបង្ហាញ ដើម្បីចៀសវាងការឆ្លងជំងឺ គឺអ្នកត្រូវការពារពិសេស នោះនៅពេលឃើញគេក្អកត្រូវបែរមុខចេញ និងនៅឲ្យឆ្ងាយពី៩០សង់ទីម៉ែត្រ ឬមួយម៉ែត្រ ៕

## ២. កោះសន្តិភាព៖ ពិភពលោកមានការព្រួយបារម្ភពីជំងឺកូរ៉ូណាថ្មី ដែលអាចផ្ទុះឡើងនៅគ្រប់កន្លែង




ក្រុមការងាររបស់អង្គការសុខភាពពិភពលោកបានចុះចតនៅប្រទេសអ៊ីតាលីកាលពីថ្ងៃច័ន្ទ ដើម្បីគាំទ្រអាជ្ញាធរអ៊ីតាលីក្នុងការស្វែងយល់អំពីស្ថានភាពនេះ។ ការផ្តោតអារម្មណ៍របស់ក្រុមនឹងផ្តោតលើ ការដាក់កម្រិតលើការឆ្លងពីមនុស្សទៅមនុស្ស បន្ទាប់ពីមានការកើនឡើងយ៉ាងឆាប់រហ័សនូវចំនួនករណី។ យ៉ាងហោចណាស់មានមនុស្ស ២៧២នាក់បានឆ្លងវីរុសនេះ ហើយមនុស្ស ៧នាក់បានស្លាប់នៅក្នុងប្រទេសនៅអឺរ៉ុបខាងត្បូង។

នៅកូរ៉េខាងត្បូងករណីជាង ៩៧០ករណី ត្រូវបានបញ្ជាក់គឺកើនឡើងពី ៣១សប្តាហ៍មុន។ យ៉ាងហោចណាស់មានមនុស្ស ១០នាក់បានស្លាប់ ហើយវីរុសបានរាលដាលពាសពេញប្រទេស ទោះបីជាការផ្ទុះឡើងដ៏អាក្រក់បំផុតនៅតែកើតមាននៅភាគខាងត្បូងទីក្រុង Daegu ក៏ដោយ។

អាជ្ញាធរចិនបានប្រកាសពីការពន្យារពេលសមាជប្រជាជនជាតិ (NPC)។ វាកើតឡើងបន្ទាប់ពីលោកប្រធានាធិបតីស៊ីជីនពីងបានព្រមានកាលពីថ្ងៃអាទិត្យថា ជម្ងឺកូរ៉ូណាថ្មីនេះគឺជាវិបត្តិសុខភាពសាធារណៈដ៏អាក្រក់បំផុត ដែលកំពុងប្រឈមមុខនឹងប្រទេស។

នៅចុងបញ្ចប់នៃថ្ងៃច័ន្ទ គណៈកម្មការសុខភាពជាតិរបស់ប្រទេសចិនបានកត់ត្រាករណីចំនួន ៧៧៦៥៨ករណីនៅចិនដីគោក និង ២៦៦៣នាក់បានស្លាប់ ។ វីរុសកូរ៉ូណាថ្មី បានឆ្លងដល់មនុស្សយ៉ាងតិច ៨០០៦៧នាក់នៅទូទាំងពិភពលោក ហើយបានសម្លាប់មនុស្សយ៉ាងហោចណាស់ ២៧០០នាក់ ៕

# ៣. ដើមអម្ពិល៖ប្រជាជនចិនដាក់ ឈ្មោះថ្មីឲ្យនាយករដ្ឋមន្ត្រីកម្ពុជាថាបុរសសង្ហាដើរបញ្ច្រាស់ទិស











ព័ត៌មានជាតិ

## ប្រជាជនចិនដាក់ ឈ្មោះថ្មីឲ្យនាយករដ្ឋមន្ត្រី កម្ពុជាថា បុរសសង្ហាដើរបញ្ច្រាស់ទិស

By CR101

Posted on February 26, 2020

LASTEST NEWS
អត្ថបទ
គម្រោង The Peak គឺជាគម្រោងអភិវឌ្ឍន៍ អគារចម្រុះ៥៥ជាន់ នៅក









9.3k Shares Share Pin Email Share Share

**ភ្នំពេញ៖** ក្នុងពិធីសម្ពោធដាក់ឱ្យ ប្រើប្រាស់ផ្លូវជាតិ លេខ៥៨ ដែលជាផ្លូវក្រវាត់ ព្រំដែនកម្ពុជា និងថៃ មានប្រវែងជាង ១៧៤គីឡូម៉ែត្រនៅព្រឹកថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០នេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានលើកឡើងថា ប្រជាជនចិន ដាក់ឈ្មោះថ្មីឲ្យសម្តេចថា បុរសសង្ហាដើរបញ្ច្រាស់ទិស។

ប្រជាជនចិនដាក់ឈ្មោះថ្មី ឲ្យនាយករដ្ឋមន្ត្រីកម្ពុជាថា បុរសសង្ហាដើរបញ្ច្រាស់ទិស ក៏ព្រោះថាប្រទេសនានា បានរើសអើងចិនបិទ ជើងហោះហើរ ជាមួយប្រទេសចិន ស្របពេលដែលចិន កំពុងជួបវិបត្តិ មេរោគកូរីន១៩ តែផ្ទុយទៅវិញ សម្តេចតេជោ ហ៊ុនសែន មិនត្រឹមតែមិនរើសអើងចិននោះទេ ថែមទាំងហ៊ាន ធ្វើដំណើរទៅទស្សនកិច្ច នៅទីក្រុងប៉េកាំង ផងដែរ។

# ៤. កម្ពុជាថ្មី៖ ក្រុមហ៊ុន Westerdam ប្រកាសថា ភ្ញៀវទេសចរទាំងអស់ និងក្រុមការងារត្រឡប់ទៅដល់ផ្ទះអស់ហើយ និងគ្មានអ្នកឆ្លងវីរុស COVID-19 ទេ




ក្រុមហ៊ុន Westerdam ប្រកាសថា ភ្ញៀវទេសចរទាំងអស់ និងក្រុមការងារនាពេលនេះបានត្រឡប់ទៅដល់ផ្ទះរៀងៗខ្លួនអស់ហើយ, គ្មានមនុស្សណាម្នាក់ឆ្លងវីរុស COVID-19 នោះឡើយ ។ នេះបើតាមទំព័រផ្លូវការនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងបានចេញផ្សាយមុននេះ។

ក្រុមហ៊ុនបានឱ្យដឹងថា ភ្ញៀវទេសចរទាំងអស់របស់កប៉ាល់ Westerdam និងក្រុមការងារដែលបានបញ្ជូនទៅកាន់កម្ពុជា នាពេលនេះបានត្រឡប់ទៅដល់ផ្ទះរៀងៗខ្លួនអស់ហើយ។ ជាថ្មីម្តងទៀត ក្រុមហ៊ុនពិតជាអរគុណដោយស្មោះចំពោះភ្ញៀវទាំងអស់សម្រាប់ ចំពោះការអត់ធ្មត់ និងយោគយល់ នៅកំឡុងស្ថានការណ៍ស្មុគស្មាញ នាពេលកន្លងទៅ។ ជាមួយគ្នានេះ ក្រុមហ៊ុនក៏សូមអរគុណជាពិសេស ដល់ក្រុមបុគ្គលិករបស់កប៉ាល់ ដែលបានផ្តល់សេវាកម្ម និងការថែទាំយ៉ាងល្អឥតខ្ចោះ។ មិនតែប៉ុណ្ណោះ ក្រុមហ៊ុនពិតជាពេញចិត្តណាស់ ចំពោះអ្នកទាំងឡាយដែលបានផ្ញើសារគាំទ្រ និងលើកទឹកចិត្ត កំឡុងពេលលំបាកមិនធម្មតានេះ។

**“សូមអរគុណដោយស្មោះចំពោះសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ព្រមទាំងក្រសួងសុខាភិបាលកម្ពុជា ក៏ដូចជាអាជ្ញាធរពាក់ព័ន្ធទាំងអស់នៅប្រទេសកម្ពុជា ដែលបានខិតខំប្រឹងប្រែង ជួយសម្របសម្រួលឱ្យភ្ញៀវរបស់យើង អាចវិលត្រឡប់ទៅដល់ផ្ទះពួកគេវិញទាំងអស់”។**

បន្ថែមពីនេះ ក្រុមហ៊ុនក៏បានអរគុណចំពោះស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា រួមជាមួយស្ថានទូតនៃប្រទេសមួយចំនួនទៀត ដែលបានផ្តល់ការជួយជ្រោមជ្រែងយ៉ាងសំខាន់ ហើយក៏មិនភ្លេចការ ខិតខំរបស់ប្រទេសហូឡង់ផងដែរ។ ជាចុងក្រោយ ក៏បានអរគុណចំពោះមន្ត្រីជំនាញមកពី អង្គការសុខភាពពិភពលោក និងមជ្ឈមណ្ឌលប្រយុទ្ធប្រឆាំងជំងឺឆ្លងអាមេរិក US-CDC សម្រាប់ការណែនាំប្រកបដោយវិជ្ជាជីវៈ។

# ៥. កម្ពុជាថ្មី៖ រោងចក្រ iPhone នៅចិនផ្តល់ប្រាក់រង្វាន់ជិត ១០០០ ដុល្លារលើកទឹកចិត្តបុគ្គលិកឱ្យចូលធ្វើការវិញ

កម្ពុជាថ្មី ប្រចាំថ្ងៃ
KAMPUCHEA THMEY DAILY



Amret mobile ចុចទីនេះដើម្បីទាញយក App Store Google play

ADVERTISER








## រោងចក្រ iphone នៅចិនផ្តល់ប្រាក់រង្វាន់ជិត ១០០០ ដុល្លារលើកទឹកចិត្តបុគ្គលិកឱ្យចូលធ្វើការវិញ

26/2/2020 8:35 Am KPT Plus, បច្ចេកវិទ្យា, ព័ត៌មានអន្តរជាតិ

LIKE

ក្រុមហ៊ុន Foxconn Technology Group ដែលជាក្រុមហ៊ុនផលិតគ្រឿងអេឡិចត្រូនិចរបស់ Apple ធំជាងគេបង្អស់លើពិភពលោកកំពុងតែផ្តល់ប្រាក់រង្វាន់ធំច្រើនដើម្បីទាក់ទាញបុគ្គលិកថ្មីឲ្យចូលធ្វើការ បន្ទាប់ពីរោងចក្ររបស់ខ្លួននៅក្នុងប្រទេសចិនត្រូវបានបិទក្នុងអំឡុងពេលជំងឺកូរ៉ូណាផ្ទុះឡើង។

ក្រុមហ៊ុនផលិតគ្រឿងអេឡិចត្រូនិចនេះបាននិយាយកាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុនថា ខ្លួននឹងចាប់ផ្តើមដំណើរការឡើងវិញនៅរោងចក្រធំៗនៅក្នុងប្រទេសចិនដោយផ្តល់ប្រាក់ឈ្នួលបន្ថែមចំនួន ៣ ០០០ យ័ន ឬ ៤២៧ ដុល្លារអាមេរិក ដល់បុគ្គលិកដែលបានវិលត្រឡប់មកវិញក្នុងរយៈពេល ៣ ខែសម្រាប់ការចាប់ផ្តើមធ្វើការ។

ឥឡូវនេះក្រុមហ៊ុនកំពុងផ្តល់ប្រាក់ឈ្នួលថ្មីនៅទីស្នាក់ការកណ្តាលក្នុងក្រុង Zhengzhou ខេត្ត Henan ដោយផ្តល់ប្រាក់លើកទឹកចិត្តចំនួន ៧ ០០០ យ័ន ឬ៩៩៥ ដុល្លារអាមេរិកប្រសិនបើបុគ្គលិកបំពេញតាមលក្ខខណ្ឌរបស់ក្រុមហ៊ុន។ នេះបើយោងតាមការចុះផ្សាយរបស់គេហទំព័រព័ត៌មានក្នុងស្រុក chinastarmarket.cn ។

យោងតាមរបាយការណ៍កាសែតហិរញ្ញវត្ថុជាតិ Business Daily នៅថ្ងៃអាទិត្យបានឲ្យដឹងថា និយោជិកថ្មីអាចទទួលបានប្រាក់លើកទឹកចិត្ត ៣ ០០០ យ័នបន្ទាប់ពីធ្វើការបាន ៦០ ថ្ងៃ និង ៤ ០០០ យ័នបន្ទាប់ពី ៩០ ថ្ងៃ ។ បើតាមការរាយការណ៍កាលពីឆ្នាំបានឲ្យដឹងដែរថា ប្រាក់ចំណូលប្រចាំខែនិយោជិកនៃរោងចក្រគឺចន្លោះពី ២០០០ ទៅ ៣០០០ យ័នតែប៉ុណ្ណោះ។

នៅក្នុងសេចក្តីថ្លែងការណ៍សរសេរឆ្លើយតបនឹងការសាកសួររបស់អ្នកសារព័ត៌មានក្រុមហ៊ុន Foxconn បានបដិសេធមិនបញ្ជាក់ពីរបាយការណ៍អំពីកញ្ចប់លើកទឹកចិត្តរបស់ខ្លួននោះទេ ដោយនិយាយថា ខ្លួនមិនបានធ្វើអត្ថាធិប្បាយលើការប៉ាន់ស្មានទីផ្សារទាក់ទងនឹងផ្នែកណាមួយនៃប្រតិបត្តិការអាជីវកម្មឡើយ។ ក្រុមហ៊ុនក៏មិនបានធ្វើអត្ថាធិប្បាយជាសាធារណៈថា តើបុគ្គលិកនឹងអាចទទួលបានលទ្ធផលយ៉ាងដូចម្តេចដែរបន្ទាប់ពីវិលចូលធ្វើការវិញ។

ក្រុមហ៊ុនផលិតគ្រឿងអេឡិចត្រូនិក Foxconn បាននិយាយថា ខណៈពេលដែលរោងចក្ររបស់ខ្លួននៅក្នុងប្រទេសចិនត្រូវបានពន្យាពេលក្នុងការវិលត្រឡប់ធ្វើប្រតិបត្តិការជាធម្មតាវិញ រោងចក្រនៅទីផ្សារផ្សេងទៀតរួមមាន វៀតណាម ឥណ្ឌា និងម៉ិកស៊ិកូកំពុងដំណើរការពេញលេញធម្មតា។

**ប្រែសម្រួល៖ សន្យា**

# ៦. កម្ពុជាថ្មី៖Covid19ព្រមានពិភពលោកឱ្យត្រៀមសម្រាប់សភាពការណ៍ដែលកាន់តែអាក្រក់ទៅៗ

កម្ពុជាថ្មី ប្រចាំថ្ងៃ
KAMPUCHEA THMEY DAILY













## covid19 ព្រមានពិភពលោកឱ្យត្រៀម សម្រាប់សភាពការណ៍ដែលកាន់តែអាក្រក់ទៅ ៗ

26/2/2020 5:12 Pm Featured, KPT Plus, ព័ត៌មានអន្តរជាតិ, សុខភាព LIKE

ADVERTISER







**ទាន់ហេតុការណ៍ពេលល្ងាច៖**

បើបុរសប្រេស៊ីលត្រូវបានគេតេស្តឃើញវិជ្ជមាននឹងក្លាយជាករណីដំបូងមួយនៅអាមេរិកខាងត្បូង ខណៈអ៊ីរ៉ង់ត្រូវបានគេចោទប្រកាន់ពីបទបិទបាំងព័ត៌មាន ឯអូស្ត្រាលីបានដាក់បម្រាមជាផ្លូវការចំពោះដំណើរទៅប្រទេសចិន ទោះបីជាអង្គការសុខភាពពិភពលោកព្រមានថា នេះជាការមាក់ងាយនិងរើសអើងធ្ងន់ធ្ងរ។

ឥឡូវក្លូរ៉ូណាវ៉ារីកំពុងវាយលុកពេញអឺរ៉ុបនិងមជ្ឈឹមបូព៌ា។ ការផ្ទុះឡើងនៅក្នុងប្រទេសអ៊ីតាលី បានបង្ហាញថា អឺរ៉ុបកំពុងចុះចាញ់ហើយ ។
ក្រុមអ្នកជំនាញនិយាយថា យើងទាំងអស់គ្នាត្រូវត្រៀម សម្រាប់សភាពការណ៍មួយដែលបង្ហាញថា គ្រប់យ៉ាងកាន់តែអាក្រក់ទៅ ៗ ។
សប្តាហ៍នេះមានការរីករាលដាលនៃករណីថ្មីឈានដល់ជាង ៣០ ប្រទេសហើយ។
អ៊ីរ៉ង់មានចំនួនអ្នកស្លាប់ខ្ពស់បំផុតលំដាប់លេខពីបន្ទាប់ចិន ចំពេលមានការអះអាងថារដ្ឋបានបិទបាំងព័ត៌មានវីរុសនេះ ដោយមានមនុស្សប្រហែលជា ៥០ នាក់ហើយដែលបានឆ្លងជំងឺនេះជាផ្លូវការ។

ប្រទេសនៅជុំវិញអឺរ៉ុប ក៏កំពុងរឹតបន្តឹងបិទព្រំដែន របស់ពួកគេ
រវាងសមាជិកក្នុងសហគមដែលកន្លងមកមិនដែលត្រូវការទិដ្ឋការចេញចូលឡើយ។ នៅមជ្ឈឹមបូពា៌វិញ
ប្រទេសទួរគី ប៉ាគីស្ថាន អ៊ីរ៉ាក់
អាហ្វហ្គានីស្ថានបានបិទការចេញចូលខណៈដែលអាជ្ញាធរបានលុបចោលការប្រគំតន្ត្រីព្រឹត្តិការណ៍កីឡានិងសាលារៀនក៏បិទ
ប្រជាជនអ៊ីរ៉ង់ចាប់ផ្តើមស្នាក់នៅក្នុងផ្ទះតាំងពីថ្ងៃចន្ទចំពេលវីរុសនេះបានវាយប្រហារសូម្បីមន្ត្រីជាន់ខ្ពស់អ៊ីរ៉ង់។
អនុរដ្ឋមន្ត្រីសុខាភិបាលអ៊ីរ៉ង់គឺលោក Iraj Harirchi ដែលបានឆ្លងវីរុសនេះហើយសមាជិកសភាម្នាក់ទៀតគឺលោក Mahmoud Sadeghi បានសរសេរនៅលើបណ្តាញ Twitter ថា“ ខ្ញុំមិនមានសង្ឃឹមច្រើនក្នុងការបានបន្តជីវិតឡើយ” ។

ផ្ទុយពីប្រទេសអ៊ីរ៉ង់ ឥណ្ឌូណេស៊ីមិនទាន់បានរាយការណ៍អំពីករណីឆ្លងវីរុសវីរុសប្រល័យលោក
នៅឡើយទេទោះបីជាគេនៅតំអក់ឃឹតយ៉ាវក្នុងការផ្អាកការហោះហើរត្រង់ពីវូហានទៅកោះបាលីក្តី។

សារព័ត៌មានស៊ីដនី Morning Herald
បានរាយការណ៍កាលពីដើមឆ្នាំនេះថាប្រទេសឥណ្ឌូនេស៊ីខ្វះឧបករណ៍ធ្វើតេស្តត្រឹមត្រូវដើម្បីកំណត់អត្តសញ្ញាណវីរុសនេះរហូតតេស្ត៍។

កូរ៉េខាងជើងបាន បិទព្រំដែនជាមួយប្រទេសចិនដែលជាសម្ព័ន្ធមិត្តសំខាន់ តាំងតែពីការផ្ទុះឡើងដំបូងដែល
ទីក្រុងព្យុងយ៉ាងបានចេញបញ្ហានេះភ្លាមៗបញ្ឈប់ទេសចរថែមទាំងលុបចោលការរត់ម៉ារ៉ាតុងប្រចាំឆ្នាំទៀត។
ជាមួយខ្សែព្រំដែនចម្ងាយប្រមាណ ១.៥០០ គីឡូម៉ែត្រជាមួយប្រទេសចិនដែលជាសម្ព័ន្ធមិត្ត គេនៅឃើញ
គមានរបៀងជាច្រើនដែលអនុញ្ញាតឱ្យមានការរត់ពន្ធមនុស្សនិងទំនិញបានបន្តនៅឡើយ។

អ្វីដែលKPTចង់សុំអ្នកអានយល់ឱ្យច្បាស់៖
ខាងលើជាព័ត៌មានពិតទាំងអស់ ដែលទាក់ទងនឹងជំងឺឆ្លងគួរតែគ្រប់ខ្មាអាចទុកជាហេតុផលក្នុងការ
ធ្វើឱ្យប្រាកដថា ខ្លួនត្រូវបានការពារ។

**ឡាហ្សូលី**

## ៧. កម្ពុជាថ្មី៖ សិង្ហបុរីកាត់ទោសដាក់ពន្ធនាគារ និងពិន័យ ៧ពាន់ដុល្លារ ចំពោះអ្នកជំងឺ Covid-19 ដែលលាក់ប្រវត្តធ្វើដំណើរ




Home > KPT Plus > សិង្ហបុរីកាត់ទោសដាក់ពន្ធនាគារ និងពិន័យ ៧ពាន់ដុល្លារ ចំពោះអ្នកជំងឺ Covid-19 ដែលលាក់ប្រវត្តិធ្វើដំណើរ

សិង្ហបុរីកាត់ទោសដាក់ពន្ធនាគារ និងពិន័យ ៧ពាន់ដុល្លារ ចំពោះអ្នកជំងឺ covid-19 ដែលលាក់ប្រវត្តិធ្វើដំណើរ

26/2/2020 4:40 Pm KPT Plus, សុខភាព LIKE

ក្រសួងសុខាភិបាលសិង្ហបុរី បាននិយាយនៅក្នុងសេចក្តីប្រកាសព័ត៌មាននៅថ្ងៃពុធនេះថា ប្រទេសសិង្ហបុរីបានចោទប្រកាន់ជនជាតិចិនពីរនាក់ ក្នុងនោះម្នាក់បានឆ្លងវីរុស Covid-19 ដោយសារការផ្តល់ព័ត៌មានមិនពិតអំពីប្រវត្តិធ្វើដំណើររបស់ពួកគេ។ អ្នកទាំង ២ មានឈ្មោះ Hu Jun អាយុ ៣៨ ឆ្នាំ ជាជនជាតិចិនមកពីទីក្រុងវ៉ូហាន និងប្រពន្ធឈ្មោះ Shi Sha អាយុ ៣៦ ឆ្នាំ ជាអ្នករស់នៅប្រទេសសិង្ហបុរី។ ទាំង Hu និង Shi បានផ្តល់ព័ត៌មានមិនពិតដល់មន្ត្រីវេជ្ជាភិបាលអំពីការផ្លាស់ទីលំនៅ និងទីកន្លែងរបស់ពួកគេពីថ្ងៃទី ២២-២៨ មករា នៅពេលពួកគេធ្វើដំណើរមកដល់។ ករណីរបស់ប្តីប្រពន្ធនេះនឹងត្រូវបើកសវនាការនៅតុលាការនៅថ្ងៃសុក្រនេះ។

គួររំលឹកថាលោក Hu ត្រូវបានគេអះអាងថា មានផ្ទុកវីរុសនេះនៅថ្ងៃទី ៣១ ខែមករា។ ក្រោយមក គាត់បានជាសះស្បើយហើយត្រូវបានចេញពីមន្ទីរពេទ្យនៅថ្ងៃទី ១៩ ខែកុម្ភៈ។

នៅក្រោមច្បាប់នៅសិង្ហបុរី សម្រាប់ជនណាម្នាក់ដែលលាក់ឬផ្តល់ព័ត៌មានមិនត្រឹមត្រូវដល់មន្ត្រីក្រសួងសុខាភិបាលក្នុងអំឡុងពេលតាមដាននៃការទំនាក់ទំនង នឹងត្រូវបានផ្តន្ទាទោសពីបទល្មើសក្រោមច្បាប់នៃការឆ្លងជំងឺរបស់ប្រទេសសិង្ហបុរី ហើយត្រូវទទួលការពិន័យជាទឹកប្រាក់រហូតដល់ ១០០០០ ដុល្លារសិង្ហបុរី (៧១៥០ ដុល្លារ) និងជាប់ពន្ធនាគាររយៈពេល ៦ ខែ។

គួរបញ្ជាក់ថាក្រសួងសុខាភិបាលសិង្ហបុរី បានរំលឹកដល់សាធារណជនថា នៅក្រោមច្បាប់ស្តីពីការឆ្លងមេរោគ វាគឺជាបទល្មើស ប្រសិនបើជនណាម្នាក់ដែលនឹងលាក់ឬផ្តល់ព័ត៌មានមិនត្រឹមត្រូវដល់មន្ត្រីក្រសួងសុខាភិបាលក្នុងអំឡុងពេលតាមដានមេរោគសញ្ញា។ ក្រសួងសុខាភិបាលចាត់ទុកសកម្មភាពបែបនេះយ៉ាងម៉ឺងម៉ាត់ ហើយនឹងមិនស្ទាក់ស្ទើរក្នុងការចាត់វិធានការសមស្របប្រឆាំងនឹងជនល្មើសឡើយ ។

## ៨. កម្ពុជាថ្មី៖ជប៉ុននឹងហាមឃាត់លែងឲ្យជនបរទេសមកពីទីក្រុងកូរ៉េ Daegu ចូលប្រទេសខ្លួន ក្រោយផ្ទុះកូរ៉ូណាខ្លាំងនៅទីនោះ



ប្រភពពីរដ្ឋាភិបាលបាននិយាយកាលពីថ្ងៃពុធថា ប្រទេសជប៉ុនគ្រោងនឹងហាមឃាត់ការចូលដោយជនជាតិបរទេសដែលបានទៅទស្សនាទីក្រុង Daegu របស់ប្រទេសកូរ៉េខាងត្បូង និងស្រុកជិតខាង Cheongdo ក្នុងខេត្ត Gyeongsang ខាងជើងដែលជាតំបន់ឆ្លងវីរុសនេះធំបំផុតនៅក្នុងប្រទេស។

ប្រភពដដែលបាននិយាយថា រដ្ឋាភិបាលរបស់លោកនាយករដ្ឋមន្ត្រី Shinzo Abe នឹងអនុម័តការហាមឃាត់ក្នុងអំឡុងកិច្ចប្រជុំមួយនៅល្ងាចនេះស្តីពីវីរុសបង្កជំងឺរលាកសួត។ ពួកគេបាននិយាយថាការហាមឃាត់ការធ្វើដំណើរចូល ដែលត្រូវបានគេរំពឹងថានឹងចូលជាធរមាននៅពាក់កណ្តាលអធ្រាត្រថ្ងៃពុធនេះ ទំនងជានឹងផ្តោតលើជនជាតិបរទេសដែលបានស្ថិតនៅក្នុងទីក្រុងឬស្រុកក្នុងរយៈពេលពីរសប្តាហ៍ បន្ទាប់ពីពួកគេបានមកដល់ប្រទេសជប៉ុន។ ផែនការនេះបានកើតឡើងមួយថ្ងៃ បន្ទាប់ពីក្រសួងការបរទេសជប៉ុនបានប្រកាសអាសន្នអំពីការធ្វើដំណើររបស់ខ្លួនសម្រាប់ទីក្រុងនិងតំបន់នៅភាគអាគ្នេយ៍នៃប្រទេសកូរ៉េ ស្នើសុំប្រជាជនជប៉ុនកុំឲ្យធ្វើដំណើរទៅតំបន់នោះដោយមិនចាំបាច់។

រហូតមកដល់ពេលនេះ ជប៉ុនបានហាមឃាត់ការចូលរបស់ជនបរទេសដែលបានស្ថិតនៅក្នុងខេត្តហ៊ូប៉ីនៃទីក្រុងវូហានរបស់ប្រទេសចិន ដែលជាចំណុចកណ្តាលនៃការផ្ទុះឡើងនិងខេត្ត Zhejiang ។

ដោយឡែកក្រុមស៊ីវិលជប៉ុនមួយបាននិយាយថា ខ្លួនបានលុបចោលផែនការបញ្ជូនសិស្សវិទ្យាល័យប្រមាណ ១៥ នាក់ទៅកូរ៉េខាងត្បូងនៅចុងខែមីនាសម្រាប់កម្មវិធីផ្លាស់ប្តូរមួយដើម្បីអំពាវនាវឱ្យលុបបំបាត់អាវុធនុយក្លេអ៊ែរ។ កម្មវិធីនេះត្រូវបានគេរៀបចំការធ្វើដំណើរជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ ២០០៣មក ។ និស្សិតទាំងនោះ គ្រោងនឹងជួបជាមួយកូរ៉េខាងត្បូងអ្នកនៅរស់រានមានជីវិតពីការទម្លាក់គ្រាប់បែកបរមាណូរបស់អាមេរិកនៅហ៊ីរ៉ូស៊ីម៉ានិងណាហ្គាសាគី និងចូលរួមក្នុងសកម្មភាពផ្សេងទៀតក្នុងដំណើរទៅប៊ូសាននិងកន្លែងផ្សេងទៀតចាប់ពីថ្ងៃទី ២៧ ដល់ថ្ងៃទី ៣០ ខែមីនា។

គួររំលឹកថា កូរ៉េខាងត្បូងបានរាយការណ៍ថាមានករណីឆ្លងវីរុសថ្មីចំនួន ១៦៩ ករណីកាលពីថ្ងៃពុធ ដែលនាំឱ្យចំនួនអ្នកឆ្លងសរុបនៅក្នុងប្រទេសមានលើសពី ១០០០ នាក់ដែលកើនឡើងតាំង ៥១ សប្តាហ៍មុន។

យោងតាមប្រព័ន្ធផ្សព្វផ្សាយកូរ៉េខាងត្បូងបានឲ្យដឹងថា ប្រហែលជា ៨០% នៃករណីដែលបានបញ្ជាក់គឺមកពី២ក្រុមដែលបង្កមាត ទី១ស្ថិតនៅព្រះវិហារមួយ នៃនិកាយសាសនានៅ Daegu និងមន្ទីរពេទ្យមួយនៅ Cheongdo ។

ប្រែសម្រួល៖សាង ស្រីល័ក្ខ

## ៩. កម្ពុជាថ្មី៖ កូរ៉ូណានៅកូរ៉េខាងត្បូងរាតត្បាតខ្លាំងដល់ជំរំទ័ព ស្របពេលអ្នកឆ្លងសរុបឡើងដល់ជាង ១១០០នាក់



ទាហានអាមេរិកម្នាក់ដែលឈរជើងក្នុងប្រទេសកូរ៉េខាងត្បូងបានធ្វើតេស្តវិជ្ជមានចំពោះវីរុសកូរ៉ូណា។ នេះបើតាមការឲ្យដឹងពីមេបញ្ជាការនៅថ្ងៃពុធ។

ទាហានដែលអាយុ២៣ឆ្នាំរូបនេះគឺជាអ្នកឆ្លងដំបូងក្នុងចំណោមកងទ័ពចំនួន ២៨ ៥០០ នាក់ដែលទីក្រុងវ៉ាស៊ីនតោនដាក់ពង្រាយក្នុងប្រទេសកូរ៉េខាងត្បូងដើម្បីការពារប្រទេសនេះប្រឆាំងនឹងប្រទេសកូរ៉េខាងជើ

កងកម្លាំងអាមេរិកបាននិយាយថា ដោយឈរជើងនៅជំរំ Camp Carroll ចម្ងាយ៣០ គីឡូម៉ែត្រភាគខាងជើងទីក្រុង Daegu ទាហានរូបនេះបានដាក់ខ្លួនឯងនៅដាច់ដោយឡែកពីគេក្នុងគេហដ្ឋានរបស់គាត់។ កងកម្លាំងអាមេរិកបានបន្ថែមថា ខ្លួនកំពុងធ្វើការតាមដានដើម្បីកំណត់ថាតើមានទាហានផ្សេងទៀតបានឆ្លងមេរោគនេះដែរឬក៏អត់។

ដោយឡែកទាហានកូរ៉េខាងត្បូងផ្ទាល់ នៅពេលនេះមាន ១៨ នាក់បានឆ្លង ដែលជំរុញឲ្យក្រសួងការពារជាតិបានដាក់កម្រិតយ៉ាងខ្លាំងទៅលើទាហានដែលចាកចេញពីមូលដ្ឋានរបស់ពួកគេ។

កាលពីព្រឹកថ្ងៃពុធនេះ អាជ្ញាធរកូរ៉េខាងត្បូងបានរាយការណ៍ពីការឆ្លងថ្មីចំនួន ១៦៩ ករណីដោយធ្វើឲ្យចំនួនសរុបឡើងដល់ទៅ ១១៤៦ករណីដែលជាចំនួនច្រើនបំផុតនៅខាងក្រៅប្រទេសចិន។

មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺកូរ៉េ (KCDC) បាននិយាយថា មនុស្សទី១១បានស្លាប់ដោយសារជំងឺនេះ។ នោះគឺជាបុរសជនជាតិម៉ុងហ្គោលីស្ថិតក្នុងវ័យ៣០ ឆ្នាំដែលបានក្លាយជាជនបរទេសដំបូងគេដែលរងគ្រោះដោយសារការផ្ទុះឡើងនេះ។

៨០ភាគរយនៃការឆ្លងថ្មីគឺនៅក្នុងទីក្រុង Daegu ដែលជាទីក្រុងធំជាងគេលំដាប់ទី៤ របស់ប្រទេសនិងជាចំណុចកណ្តាលនៃការផ្ទុះឡើងនិងនៅក្នុងខេត្ត Gyeongsang ខាងជើង។

ផ្លូវនានានៃទីក្រុង Daegu ដែលមានប្រជាជនចំនួន២.៥ លាននាក់ត្រូវបានគេបោះបង់ចោលអស់រយៈពេលជាច្រើនថ្ងៃមកហើយលើកលែងតែនៅតាមហាងដែលមានលក់ម៉ាស់ប៉ុណ្

អាជ្ញាធរបានជំរុញឲ្យសាធារណជនមានការប្រុងប្រយ័ត្នបន្ថែមហើយណែនាំដល់ប្រជាពលរដ្ឋឲ្យស្នាក់នៅក្នុងផ្ទះប្រសិនបើពួក

ប៉ុន្តែពួកគេនិយាយថា ពួកគេមិនពិចារណាដាក់ទីក្រុងនេះក្នុងការឡោមព័ទ្ធដូចដែលចិនបានធ្វើចំពោះទីក្រុង Wuhan នោះទេ។ AFP

**ប្រែសម្រួល៖ វណ្ណវណ្ណ**

## ១០. កម្ពុជាថ្មី៖ ជម្លោះរវាងសាសនានិងវិទ្យាសាស្ត្រពីវីរុស Covid-19 ដែលកំពុងតែរាលដាលក្នុងប្រទេសអ៊ីរ៉ង់



ផ្អែកតាមការចុះផ្សាយរបស់ BBC របាយការណ៍ពីទីក្រុងនានាជុំវិញប្រទេសអ៊ីរ៉ង់បានបង្ហាញថា ចំនួនករណីឆ្លងនៅប្រទេសអ៊ីរ៉ង់គឺពិតជាខ្ពស់ជាង ៩៥ករណីដែលអាជ្ញាធរអ៊ីរ៉ង់បានផ្តល់ឱ្យ។ មិនដូចនៅប្រទេសអ៊ីតាលីទេ មន្ត្រីអ៊ីរ៉ង់កំពុងបដិសេធក្នុងការដាក់ឱ្យនៅដាច់ពីគេនៅក្នុងតំបន់ដែលរងផលប៉ះពាល់ពីការផ្ទុះឡើងនេះ។ ក្រុមអ្នកនិយមសាសនាបាននិយាយថា ការដាក់ឱ្យនៅដាច់ពីគេ គឺជាគំនិតចាស់គំរិលហើយពួកគេមិនជឿលើរឿងរ៉ាវទាំងអស់នេះឡើយ។

ទីសក្ការបូជា Shiaមួយនៅក្នុងទីក្រុង Qom និងទីក្រុង Mashhad នៅតែបើកបើទោះបីជាទីក្រុង Qom ជាកន្លែងផ្ទុកវីរុសនិងជាកន្លែងកំពុងតែក្តៅគគុកក៏ដោយ។

គួរបញ្ជាក់ថា Ayatollahs គឺជាបព្វជិតជាន់ខ្ពស់ដែលជឿថាទីសក្ការបូជាគឺជាកន្លែងទាក់ទាញអ្នកធ្វើធម្មយាត្រារាប់លាននាក់មកពីជុំវិញពិភពលោក ហើយថ្នាក់សិក្ខាសាលាសំខាន់ៗ ដែលមាននិស្សិតសាសនាបរទេសជាច្រើនគឺមានមោទនភាពហើយមិនមានរឿងអ្វីកើតឡើងឡើយ។

ក្រុមអ្នកជំនាញបានសន្និដ្ឋានថា មូលហេតុដែលអ៊ីរ៉ង់ព្យាយាមបិទព័ត៌មានដែលផ្តើមចេញពីជំហានធំពីបព្វជិតដែលជាក្រុមនិយមសាសនាឥស្លាម ហើយគេជឿជាក់ថាមិនមែនជាជំហានដែលពួកគេអាចនឹងធ្វើបាននោះទេ លើកលែងតែពួកគេស្ថិតក្រោមសម្ពាធអន្តរជាតិណាមួយ។ យើងអាចឃើញជម្លោះរវាងអ្នកអភិរក្សសាសនានិងវិទ្យាសាស្រ្តបានខ្វែងគំនិតខ្លាចំពោះវីរុស ដែលកំពុងរីករាលដាលពាសពេញប្រទេស។ អ៊ីរ៉ង់ក៏ជាប្រទេសខ្វះឧបករណ៍វេជ្ជសាស្រ្តគ្រប់គ្រាន់ ដើម្បីជួយទប់ទល់នឹងការផ្ទុះឡើងនេះដែរ ចំណែកម៉ាសការពារហើយនិងឧបករណ៍សម្រាប់ធ្វើតេស្តក៏មិនសូវមានគ្រប់គ្រាន់ដូចគ្នា។ បុគ្គលិកពេទ្យមួយចំនួនក៏បានឆ្លងជំងឺផងដែរ ដូច្នេះមានការព្រួយបារម្ភថាពួកគេនឹងឆាប់រត់ចេញពីតួនាទីគ្រូពេទ្យនិងគិលានុបដ្ឋាយិកាដើម្បីទៅធ្វើជាជំងឺម្តង។

ប្រជាជនអ៊ីរ៉ង់ភាគច្រើនមានការព្រួយបារម្ភយ៉ាងខ្លាំង តែស្ថានការណ៍ហាក់ស្ងប់ស្ងាត់ទៅវិញ។ លេខាធិការនៃក្រុមប្រឹក្សាសន្តិសុខជាតិជាន់ខ្ពស់អ៊ីរ៉ង់លោក Ali Shamkhani បាននិយាយនៅថ្ងៃអង្គារម្សិលមិញថាលោកបានស្នើសុំឱ្យអគ្គព្រះរាជអាជ្ញា“ ពិនិត្យមើលសុពលភាព” នៃការចោទប្រកាន់របស់សមាជិកសភាដែលកំពុងតែមានការចលាចលថាសមាជិកសភាកំពុងឆ្លងវីរុសសាហាវមួយនេះ។

គួររំលឹកដែរថា សមាជិកសភាម្នាក់មកពីរដ្ឋធានី Tehran របស់អ៊ីរ៉ង់គឺលោក Mahmoud Sadeghi បាននិយាយថាលោកក៏បានធ្វើតេស្តវិជ្ជមានចំពោះវីរុសនេះផងដែរ។

**តើករណីអាចរាលដាលពាសពេញមជ្ឈិមបូព៌ាបានទេ នៅពេលដែលវិវាទវិទ្យាសាស្រ្តនិងសាសនាកំពុងកើតឡើងក្នុងប្រទេស?**

អ៊ីរ៉ង់ត្រូវបានគេជឿថាជាប្រភពនៃករណីដំបូងដែលរាយការណ៍ដោយប្រទេសជិតខាង អាហ្វហ្គានីស្ថានបារ៉ែន អ៊ីរ៉ាក់ គុយវ៉ែត និងអូម៉ង់ ដែលឥឡូវនេះបានដាក់កម្រិតលើការធ្វើដំណើរទៅនិងមកពីសាធារណរដ្ឋអ៊ីស្លាម។ ប្រជាជនអ៊ីរ៉ង់មួយចំនួន បានភ័យខ្លាចថាអ្នកធ្វើធម្មយាត្រា Shia របស់ម៉ូស្លីមនិងពលករចំណាកស្រុកជាច្រើនដែលនឹងធ្វើដំណើររវាងអ៊ីរ៉ង់និងផ្នែកផ្សេងទៀតនៃតំបន់ក្នុងប៉ុន្មានសប្តាហ៍ថ្មីៗនេះ អាចនឹងឆ្លងវីរុសនេះរួចទៅហើយ។

ក្រុមអ្នកជំនាញបាននិយាយថា នៅក្នុងប្រទេសនានាដូចជាប្រទេសអាហ្វហ្គានីស្ថាន ដែលបានហែកហួរដោយសង្គ្រាមរាប់ឆ្នាំ បានរាយការណ៍ថា មានតែមួយករណីប៉ុណ្ណោះ អាជ្ញាធរសុខាភិបាលនឹងព្យាយាមតាមដាននិងធ្វើតេស្តទំនាក់ទំនងមនុស្សដែលឆ្លងជំងឺនេះឲ្យបានពិតដល់ ។

**ចុចអាន៖› អ៊ីរ៉ង់ពេលនេះមានចំនួនអ្នកស្លាប់ដោយសារវីរុស Covid-19 ខ្ពស់បំផុតបន្ទាប់ពីប្រទេសចិន**

**ចុចអាន៖អនុរដ្ឋមន្ត្រីក្រសួងសុខាភិបាលអ៊ីរ៉ង់ ធ្វើតេស្តវិជ្ជមានវីរុស Covid-19 ខណ:ការរីករាលដាលកាន់តែអាក្រក់ទៅ ៗ**

## ១១. រស្មីកម្ពុជា៖ រដ្ឋមន្ត្រីឲ្យអង្គសន្និបាតពិភាក្សាស្វែងរកវិធានការគន្លឹះនានាក្នុងដំណាក់កាលវិបត្តិ Covid-19




***ដោយៈ មូលសម្បត្តិ/ភ្នំពេញ*** ៖ ក្នុងសន្និបាតបូកសារុបប្រចាំឆ្នាំមើលលទ្ធផលការងារឆ្នាំ2019 និងដាក់ទិសដៅឆ្នាំ2020នៅព្រឹកថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០២០ នេះ លោកថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានលើកយកបញ្ហាវិបត្តិផ្ទុះជម្ងឺកូរ៉ូណាមកអោយអង្គសន្និបាតពិភាក្សារកវិធីដោះស្រាយ ក្រោមការណែនាំពីនាយករដ្ឋមន្ត្រីរួចមក។

លោកលើកឡើងថា នៅដើមឆ្នាំ២០២០ នេះ វិស័យទេសចរណ៍សកលលោក ក៏ដូចជាតំបន់ និងកម្ពុជា បាននិងកំពុងទទួលរងឥទ្ធិពលអវិជ្ជមានពីវិបត្តិនៃជំងឺរលាកសួតវីរុសកូរ៉ូណាប្រភេទ ថ្មី (COVID-19) ដោយអង្គការទេសចរណ៍ពិភពលោក (UNWTO) បានស្នើឲ្យប្រទេសជាសមាជិកត្រូវមានការប្រុងប្រយ័ត្ន ចូលរួមទប់ស្កាត់ និងបង្ការជំងឺឆ្លងកូរ៉ូណាថ្មីនេះ និងស្នើឲ្យវិស័យឧស្សាហកម្មទេសចរណ៍ត្រូវអនុវត្តតាមការណែនាំរបស់អង្គការសុខភាពពិភពលោក (WHO) ឬក្រសួងសុខាភិបាលតាមប្រទេសនីមួយៗឲ្យបានជាប្រចាំ ពីព្រោះថា “ទោះស្ថិតក្នុងស្ថានភាពនៃវិបត្តិក៏ដោយ ការធ្វើដំណើររបស់ទេសចរនៅតែអាចធ្វើទៅបាន ដោយ ត្រូវអនុវត្តនូវវិធានការបង្ការទប់ស្កាត់ឲ្យបានខ្ជាប់ខ្ជួន តាមការណែនាំរបស់អង្គការសុខភាពពិភពលោក (WHO)”។

ឆ្លើយតបនឹងសភាពការណ៍ Covid-19 នេះ សម្តេចតេជោ ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាល កាលពីថ្ងៃទី២៤ ខែកុម្ភៈ នេះក៏ បានដាក់ចេញនូវវិធានការគាំទ្រវិស័យទេសចរណ៍ចំនួន ០៧ចំនុច ដែលក្រសួងទេសចរណ៍នឹងប្តេជ្ញាសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងផ្នែកឯកជន អនុវត្តវិធានការទាំង០៧ចំនុចនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់។

ទន្ទឹមនឹងនេះ ក្រសួងទេសចរណ៍ ក្នុងនាមសេនាធិការ ក៏បានដាក់ចេញ « ផែនការសកម្មភាពការងារទេសចរណ៍អនុវត្តចំពោះមុខក្នុងដំណាក់កាលវិបត្តិវីរុសកូរ៉ូណាថ្មី (COVID-19) ២០២០-២០២១» ដែលផ្តោតលើគោលដៅយុទ្ធសាស្ត្រចំនួន ៤៖
១). ធ្វើឲ្យរូបភាពគោលដៅទេសចរណ៍កម្ពុជា (Improve Image) គឺជាគោលដៅសុវត្ថិភាពកាន់តែប្រសើរឡើង
២). ជម្រុញចលនាទេសចរណ៍ក្នុងស្រុក
៣). បង្កើនការផ្សព្វផ្សាយទេសចរណ៍ និងការតភ្ជាប់ (Connectivity) ពីទីផ្សារទេសចរណ៍គោលដៅ
៤). បង្កើតឧត្តមភាពប្រកួតប្រជែងនៃឧស្សាហកម្មទេសចរណ៍ និងបានដាក់ចេញសកម្មភាពបន្ទាន់ នៅក្នុងរយៈពេលខ្លី និងមធ្យមចំនួន ៩០ សកម្មភាព។

លោករដ្ឋមន្ត្រីបានស្នើឲ្យអង្គសន្និបាតយកចិត្តទុកដាក់ពិភាក្សា ផ្លាស់ប្តូរយោបល់គ្នាឲ្យបានផុលផុសដើម្បីទទួលបានទស្សនៈ និងធាតុចូលថ្មីៗបន្ថែមទៀតក្នុងការស្វែងរកវិធានការគន្លឹះនានាក្នុងដំណាក់កាលវិបត្តិ Covid-19 នេះ។

ជារួមរាជរដ្ឋាភិបាល ក្រសួងទេសចរណ៍ គឺបានកំណត់ទិសដៅក្នុងការអភិវឌ្ឍ “ទេសចរណ៍គុណភាព” នៅកម្ពុជា សំដៅប្រែក្លាយកម្ពុជាជាគោលដៅប្រកបដោយគុណភាព ភាពទាក់ទាញ កក់ក្តៅ និងបដិសណ្ឋារកិច្ចល្អ។/B

## ១២. រស្មីកម្ពុជា៖ ក្រសួងរៀបយុទ្ធសាស្ត្រថ្មីទប់ទល់និងវិបត្តិវីរុសកូរ៉ូណា (Covid-19)-EBA ដើម្បីរកកំណើនទេសចរ

រស្មីកម្ពុជា







### ក្រសួងរៀបយុទ្ធសាស្ត្រថ្មីទប់ទល់និងវិបត្តិវីរុសកូរ៉ូណា (Covid-19)-EBA ដើម្បីរកកំណើនទេសចរ




***ដោយ: មូលសម្បត្តិ / ភ្នំពេញ:*** អនុវត្តតាមសាររបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០២០ ស្តីពីវិធានការរបស់រាជរដ្ឋាភិបាលដើម្បីគ្រប់គ្រងផលប៉ះពាល់ពីជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ (ខូវីដ-១៩) និងការព្យួរភាពអនុគ្រោះពន្ធលើទំនិញមួយចំនួនក្រោមកម្មវិធី ទំនិញគ្រប់មុខ លើកលែងអាវុធ (EBA) នាព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ លោកថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងារបន្ទាន់មួយ ស្តីពីការអនុវត្តផែនការសកម្មភាពការងារចំពោះមុខ ដើម្បីទប់ទល់វិបត្តិជំងឺឆ្លងកូរ៉ូណាថ្មី (Covid-19) ដែលផែនការនេះ មានគោលដៅយុទ្ធសាស្ត្រចំនួន ៤ និងសកម្មភាពអនុវត្តចំនួន ៩០។



ដើម្បីអនុវត្តផែនការនេះឲ្យមានប្រសិទ្ធភាព ក្រសួងបានរៀបចំបង្កើតក្រុមការងារមួយដើម្បីជម្រុញ និងលើកស្ទួយ វិស័យទេសចរណ៍ក្នុងដំណាក់កាល និងក្រោយវិបត្តិនៃវីរុសកូរ៉ូណាថ្មី (Covid-19) ដែលមានរដ្ឋលេខាធិការប្រចាំការ ០១រូប ជាប្រធាន ។រដ្ឋលេខាធិការ ០២រូប ជាអនុប្រធាន និងមានអនុរដ្ឋលេខាធិកា អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋានពាក់ព័ន្ធមួយចំនួន និងប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត ជាសមាជិក។ ក្រុមការងារនេះមានលេខាធិការដ្ឋានមួយ ជាសេនាធិការ និងបែងចែកជាអនុក្រុមការងារចំនួន ០៥ រួមមាន៖

- អនុក្រុមការងារទី១- ជម្រុញចលនាទេសចរណ៍ក្នុងស្រុក និងពង្រឹងគុណភាពឧស្សាហកម្មទេសចរណ៍ (ដឹកនាំដោយ លោក សុង តុងហាប់ អនុរដ្ឋលេខាធិការ)។
- អនុក្រុមការងារទី២- បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពអ្នកជំនាញទេសចរណ៍ (ដឹកនាំដោយ លោកប៉ាក់ សុខុម រដ្ឋលេខាធិការ)។
- អនុក្រុមការងារទី៣- រៀបចំព្រឹត្តិការណ៍ (ដឹកនាំដោយ លោក តុប សុភ័ក អនុរដ្ឋលេខាធិការ)។
- អនុក្រុមការងារទី៤- ជម្រុញចលនាផ្សព្វផ្សាយក្រៅប្រទេស និងបញ្ជ្រាបការយល់ដឹងជាសាធារណៈកម្ពុជាជាគោលដៅទេសចរណ៍សុវត្ថិភាពក្នុងដំណាក់កាលវិបត្តិ (ដឹកនាំដោយលោកថោង រដ្ឋសក្តិ អគ្គនាយកអភិវឌ្ឍន៍ទេសចរនិងសហប្រតិបត្តិការអន្តរជាតិ)
- អនុក្រុមការងារទី៥- សម្រួលការធ្វើដំណើរ និងសុវត្ថិភាពនៃការធ្វើដំណើរ (ដឹកនាំដោយ លោកហោ សារុន អនុរដ្ឋលេខាធិការ)៕ ល

## ១៣. រស្មីកម្ពុជា៖ ភាគហ៊ុននិងប្រេងធ្លាក់ថ្លៃ៣ថ្ងៃជាប់គ្នា ដោយសារខ្លាចវីរុស




ភាគហ៊ុននិងប្រេងបានធ្លាក់ថ្លៃ៣ថ្ងៃជាប់គ្នាគិតត្រឹមថ្ងៃពុធទី២៦កុម្ភៈដោយសារតែការភ័យខ្លាចកាន់តែកើនឡើងថាការឆ្លងរាលដាលក្លូរ៉ូណាវីរុសទំនងជាមិនអាចទប់ស្កាត់បាន ដោយវានឹងប៉ះពាល់កំណើនសេដ្ឋកិច្ចសកល។

ថ្លៃហ៊ុន Nikkei ជប៉ុនចុះ០,៨ភាគរយ S&P/ASXអូស្ត្រាលីចុះ២,៣ភាគរយ Kospi របស់កូរ៉េខាងត្បូងចុះ១ភាគរយ និងHang Seng នៅហុងកុងក៏ដូចThe Shanghai Compositeនៅក្រុងសៀងហៃចុះ០,៨ភាគរយ។

នៅតៃវ៉ាន់និងអាស៊ីអាគ្នេយ៍ ភាគហ៊ុនក៏ធ្លាក់ថ្លៃ នៅពេលផ្សារWall Streetអាម៉េរិក សន្ទស្សន៍ហ៊ុន S&P 500 បានបាត់បង់តំលៃអស់៧,៦ភាគរយនៅ៤ថ្ងៃមកនេះ។

ចំណែកប្រេងនៅផ្សារអាម៉េរិកចុះ៦៤សេនមកនៅត្រឹម៤៩,៨៦ដុល្លារក្នុងមួយបារ៉ែល និងប្រេងនៅផ្សារអាស៊ីចុះ១៦សេនមកនៅត្រឹម៥៤,១០កាលពីថ្ងៃអង្គារ។

សូមបញ្ជាក់ថា ដោយសារតែមានការបារម្ភថាការផ្ទុះជម្ងឺឆ្លងបច្ចុប្បន្ននឹងប៉ះពាល់តំរូវការប្រេង វាបានធ្វើអោយប្រេងធ្លាក់ថ្លៃអស់ជិត១០ដុល្លារក្នុងមួយបារ៉ែលនៅឆ្នាំនេះ ទោះជាបិទការផ្គត់ផ្គង់ប្រេងពីលីប៊ីភាគច្រើន និងអង្គការនាំចេញប្រេងOpecរួមជាមួយសម្ពន្ធមិត្តរុស្ស៊ី ព្រមព្រៀងគ្នាដើម្បីកាត់បន្ថយផលិតកម្មប្រេងក្តី។ប្រែសម្រួល៖វាសនា

## ១៤. រស្មីកម្ពុជា៖ ការធ្វើតេស្តវ៉ាក់សាំងវីរុសកូរ៉ូណាលើមនុស្សនឹងចាប់ផ្តើមនៅសហរដ្ឋអាម៉េរិកឆាប់ជាងការរំពឹងទុក




ក្រុមហ៊ុនផលិតឱសថ Moderna បានបញ្ជូនថ្នាំវ៉ាក់សាំងការពារវីរុសកូរ៉ូណាដំបូងរបស់ខ្លួនឱ្យទៅក្រុមអ្នកស្រាវជ្រាវរបស់រដ្ឋាភិបាលដើម្បីធ្វើតេស្តពេលគឺត្រឹម ៣ ខែប៉ុណ្ណោះបន្ទាប់ពីហ្សែនរបស់វីរុសកូរ៉ូណាថ្មីនេះបានកកើតឡើង។

ភាគហ៊ុនរបស់ក្រុមហ៊ុនជីវបច្ចេកវិជ្ជាមួយនេះបានកើនឡើងយ៉ាងខ្លាំងកាលពីព្រឹកថ្ងៃអង្គារទី២៥កុម្ភៈ គឺមួយថ្ងៃគត់បន្ទាប់ពីក្រុមហ៊ុននេះបាននិយាយថាខ្លួនបានផ្ញើដបថ្នាំវ៉ាក់សាំងទៅវិទ្យាស្ថានជាតិអាឡែរស៊ីនិងជំងឺឆ្លងដើម្បីធ្វើតេស្តនៅដំណាក់កាលដំបូងនៅសហរដ្ឋអាម៉េរិក។

មនុស្សជាង ៨០.០០០ នាក់បានឆ្លងរោគនេះនៅទូទាំងពិភពលោក ក្រោយវាផ្ទុះឡើងកាលពីចុងឆ្នាំមុននៅក្នុងប្រទេសចិន។

សរុប ៣៥ ករណីត្រូវបានរាយការណ៍នៅសហរដ្ឋអាម៉េរិក ហើយមនុស្សជាង ២.៦០០ នាក់បានស្លាប់ដោយសារវីរុសកូរ៉ូណានៅចិនដីគោក ក្នុងនោះមានពលរដ្ឋអាម៉េរិកម្នាក់ផងដែរ។

វ៉ាក់សាំងនេះត្រូវបានបង្កើតឡើងដើម្បីកម្ចាត់ប្រូតេអ៊ីន Spike នៅលើផ្ទៃនៃមេរោគ។ ប្រូតេអ៊ីននេះហើយដែលអនុញ្ញាតឱ្យមេរោគវាយលុកនិងឆ្លងចូលកោសិការបស់មនុស្ស។

ក្រុមអ្នកជំនាញធ្លាប់បានប្រាប់កាសែតដេលីមែលថា វឌ្ឍនភាពរបស់វ៉ាក់សាំងរំកិលទៅមុខយ៉ាងលឿន ប៉ុន្តែគេត្រូវចំណាយពេល ១៨ ខែឬច្រើនជាងនេះដើម្បីឱ្យវ៉ាក់សាំងដាក់ប្រើជាផ្លូវការបាន ទោះបីវាបង្ហាញពីសុវត្ថិភាពសម្រាប់ការប្រើប្រាស់ចំពោះមនុស្សក៏ដោយ៕ ដោយ៖ កញ្ញាដាលីស

# ១៥. រស្មីកម្ពុជា៖ ពីមុនកូរ៉េធ្វើចត្តាឡីស័កអ្នក ដំណើរពីចិន ឥឡូវចិនធ្វើចត្តាឡីស័កអ្នកដំណើរ មកពីកូរ៉េ នៅពេលអ្នកឆ្លងកើនជាង១ពាន់នាក់





ជំណឹងអន្តរជាតិ

## ពីមុនកូរ៉េធ្វើចត្តាឡីស័កអ្នក ដំណើរពីចិន ឥឡូវចិនធ្វើចត្តាឡីស័កអ្នកដំណើរមកពីកូរ៉េ នៅពេលអ្នកឆ្លងកើនជាង១ពាន់នាក់

February 26, 2020, 9:42 AM

101




ចិនបានធ្វើចត្តាឡីស័ក(ដាក់នៅដាច់ពីគេដើម្បីតាមដាននិងពិនិត្យសុខភាព)លើអ្នកដំណើរ៩៤នាក់នាក់មកពីក្រុងសេអ៊ូល បន្ទាប់ពីអ្នកដំណើរជនជាតិចិនបីនាក់បង្ហាញរោគសញ្ញាក្តៅខ្លួន នេះបើតាមការផ្សាយរបស់ទូរទស្សន៍រដ្ឋចិនCCTV កាលពីព្រឹកថ្ងៃពុធទី២៦កុម្ភៈ។

យន្តហោះនៃជើងហោះហើរFlight OZ349 មកពីក្រុងសេអ៊ូលបានចុះចតនៅទីក្រុងណាននីញភាគខាងកើតចិនកាលពីរសៀលថ្ងៃអង្គារ។

CCTVបាននិយាយថា អ្នកដំណើរជនជាតិចិនទាំងបីនាក់ដែលក្តៅខ្លួន មិនដែលបានទៅឬមានទំនាក់ទំនងជាមួយក្រុងវូហាន ដែលជាប្រភពផ្ទុះCovid-19 ឬក៏ខេត្តហ៊ូប៉ីទេនៅពេលថ្មីៗនេះ។

កូរ៉េខាងត្បូង ឥឡូវក្លាយជាកន្លែងផ្ទុះជំងឺឆ្លងនេះធំជាងគេនៅក្រៅចិនដីគោក ដោយកាលពីថ្ងៃពុធអាជ្ញាធរបានប្រកាសថាមានអ្នកឆ្លងថ្មីចំនួន១៦៩នាក់ទៀត ដែលនាំឲ្យចំនួនអ្នកឆ្លងCovid-19នៅទូទាំងកូរ៉េខាងត្បូងកើនដល់១.១៤៦នាក់។

ជនទី១១បានស្លាប់ដោយជំងឺឆ្លងនេះនៅកូរ៉េខាងត្បូងកាលពីថ្ងៃអង្គារ។

ក្នុងពេលជាមួយគ្នា អាជ្ញាធរបានទទូចឲ្យសាធារណជនមានការប្រុងប្រយ័ត្នខ្ពស់ ដោយណែនាំឲ្យប្រជាជននៅក្នុងផ្ទះបើក្តៅខ្លួន ឬចេញរោគសញ្ញាផ្លូវដង្ហើម។សភាកូរ៉េខាងត្បូងក៏លុបចោលសម័យប្រជុំកាលពីថ្ងៃអង្គារ ដោយសារអគារសភាបិទទ្វារដើម្បីធ្វើអនាម័យក្រោយពីមានរបាយការណ៍ថាមនុស្សឆ្លងវីរុសម្នាក់បានចូលប្រជុំក្នុងសភា៕ប្រែសម្រួល៖***ភិសនា***/Ha